ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១៦**

# សេចក្តីថ្លែងការណ៍

## របស់ការិយាល័យសហព្រះរាជអាជ្ញាក្នុងសំណុំរឿង ០០៤/០១

## វិធាន៥៤ សេចក្តីសង្ខេបរបស់សហព្រះរាជអាជ្ញាស្តីពីដីកាសន្និដ្ឋានស្ថាពរពាក់ព័ន្ធនឹង អ៊ឹម ចែម

វិធាន៥៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ចែងថា ខណៈដែលដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាគឺជាឯកសារសម្ងាត់ "ប៉ុន្តែដោយគិតដល់តម្រូវការក្នុងការផ្តល់ព័ត៌មានដល់សាធារណជនអំពីវិវឌ្ឍនភាពនៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ សហព្រះរាជអាជ្ញាអាចផ្តល់ឲ្យសាធារណជននូវព័ត៌មានសង្ខេប ដែលមាននៅក្នុងដីកានេះ..."។ សេចក្តីសង្ខេបខាងក្រោមរបស់សហព្រះរាជអាជ្ញា ស្តីពីដីកាសន្និដ្ឋានស្ថាពរពាក់ព័ន្ធនឹងកិច្ចស៊ើបសួរលើ អ៊ឹម ចែម ត្រូវបានចេញដោយយោងទៅតាមវិធាននេះ ហើយជំនឿរបស់សហព្រះរាជអាជ្ញា ដែលថា តម្លាភាពនឹងធ្វើជាវិភាគទានដល់ទំនុកចិត្តរបស់សាធារណជន នៅក្នុងស្ថាប័នតុលាការ។

សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ក្នុងសំណុំរឿង០០៤/០១ ជាកិច្ចស៊ើបសួរលើ អ៊ឹម ចែម កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦។ ឥឡូវនេះ វាអាស្រ័យលើសហចៅក្រមស៊ើបអង្កេតសម្រេចថាតើ អ៊ឹម ចែម ជាបុគ្គលម្នាក់ដែលជាប្រធានបទនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដែរឬទេ និងថាតើកិច្ចស៊ើបសួរបានបង្កើតឡើងនូវការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. បានដល់កម្រិតមួយដែលតម្រូវឲ្យកោះហៅគាត់ឲ្យចូលខ្លួនពីបទចោទប្រកាន់ និងបញ្ជូនគាត់ទៅជំនុំជម្រះ ដែរឬទេ។ ដូច

ដែលរាល់ជនត្រូវចោទ ឬជនជាប់ចោទទាំងអស់នៅ អ.វ.ត.ក. ដូច្នោះដែរ អ៊ឹម ចែម ត្រូវបានរក្សាទុកនូវសច្ចធារណ៍នៃនិរទោស ដែលនឹងត្រូវបានលើក ប្រសិនបើ និងនៅពេលណាដែលកំហុសរបស់គាត់ត្រូវបានបង្ហាញនៅពេលសវនាការ និងឆ្លងកាត់បណ្តឹងឧទ្ធរណ៍។

សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែក នៅក្នុងករណីប្រឆាំងនឹង អ៊ឹម ចែម ដោយផ្ទុះបញ្ចាំងនូវទស្សនៈដាច់ដោយឡែករបស់ខ្លួន នៅលើសំណុំរឿង។ សហព្រះរាជអាជ្ញាជាតិបានសន្និដ្ឋានថា អនុលោមតាមច្បាប់គ្រប់គ្រង អ.វ.ត.ក. អ៊ឹម ចែម មិននៅក្នុងប្រភេទបុគ្គលដែល អ.វ.ត.ក. មានយុត្តាធិការលើនោះទេ ដោយហេតុថាគាត់មិនមែនជា "មេដឹកនាំជាន់ខ្ពស់" នៃរបបកម្ពុជាប្រជាធិបតេយ្យ ("DK") និងមិននៅក្នុងចំណោមបុគ្គល "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ សហព្រះរាជអាជ្ញាអន្តរជាតិបានសន្និដ្ឋានថា តាមទស្សនៈរបស់គាត់ទៅលើភស្តុតាង ខណៈដែល អ៊ឹម ចែម មិនមែនជា "អ្នកដឹកនាំជាន់ខ្ពស់" គាត់គឺនៅក្នុងចំណោមបុគ្គល "ដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅក្នុងអត្ថន័យនៃច្បាប់គ្រប់គ្រង អ.វ.ត.ក. ហើយដូច្នេះ លក្ខខណ្ឌតម្រូវនៃយុត្តាធិការបុគ្គល គឺឆ្លើយតបត្រឹមត្រូវហើយ។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានផ្តល់ផងដែរនូវការវិភាគរបស់ខ្លួនលើភស្តុតាងដែលបានប្រមូលនៅក្នុងកិច្ចស៊ើបសួរ និងមានការពន្យល់មួយនៅក្នុងទស្សនៈរបស់គាត់ថាមកពីហេតុអ្វី បានបង្ហាញនូវការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរមួយចំនួននៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក.។

*សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាជាតិ*

លទ្ធផលតាំងពីដំបូងនៃការស៊ើបអង្កេតបឋម និងរហូតមកដល់ការបិទកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញាជាតិបានពិនិត្យ និងមានជំហរយ៉ាងច្បាស់ថា មានតែជនជាប់ចោទដែលមានស្រាប់នៅ អវតក ប៉ុណ្ណោះជាមេដឹកនាំជាន់ខ្ពស់ និងជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះគួរតែផ្តល់អាទិភាពទៅលើការវិនិច្ឆ័យទោសជនជាប់ចោទទាំងនេះ ដើម្បីបំពេញឲ្យបានគ្រប់គ្រាន់ចំពោះអាណត្តិរបស់តុលាការនេះ ដោយហេតុថា ច្បាប់ អវតក និង កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានគិតទុកជាមុនអំពីការវិនិច្ឆ័យទោសចំពោះតែមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ។

យោងតាមច្បាប់ អ.វ.ត.ក និង កិច្ចព្រមព្រៀងដែលអង្គការសហប្រជាជាតិបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខនោះ បានតម្រូវឲ្យសហព្រះរាជអាជ្ញា ជ្រើសរើសយកបុគ្គលតែពីរប្រភេទប៉ុណ្ណោះមកធ្វើការវិនិច្ឆ័យសេចក្តីគឺ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

ហេតុដូច្នេះ សហព្រះរាជអាជ្ញាជាតិ ប្រកាន់ជំហរថា ឈ្មោះ អ៊ឹម ចែម ដែលស្ថិតនៅក្នុងសំណុំរឿងលេខ ០០៤/១ មិនស្ថិតនៅក្នុងយុត្តាធិការបុគ្គល របស់ អ.វ.ត.ក ដែលត្រូវយកមកធ្វើការកាត់សេចក្តីឡើយ។

*សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ*

សហព្រះរាជអាជ្ញាអន្តរជាតិទទួលស្គាល់ថា អ៊ឹម ចែម មិនធ្លាប់កាន់មុខតំណែងជាសមាជិកនៃគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមរបស់កម្ពុជាប្រជាធិបតេយ្យ នោះទេ, គាត់មិនមែនជាលេខាភូមិភាគ ឬលេខាតំបន់ នៅក្នុងឋានានុក្រមបក្សកុម្មុយនីសកម្ពុជា (“បកក”) នោះទេ ហើយក៏មិនមែនជាមន្ត្រីជាន់ខ្ពស់ នៅក្នុងកងកម្លាំងយោធារបស់ បកក ដែរ។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា អ៊ឹម ចែម មិនមែនជា “មេដឹកនាំជាន់ខ្ពស់” នៃកម្ពុជាប្រជាធិបតេយ្យ នៅក្នុងអត្ថន័យនៃច្បាប់គ្រប់គ្រង អ.វ.ត.ក។

យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា ភស្តុតាងបានបង្ហាញថា អ៊ឹម ចែម ត្រូវទៅតាមលក្ខណៈវិនិច្ឆ័យទីពីរសម្រាប់ដាក់បញ្ចូលទៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. ដោយសារតែគាត់នៅក្នុងចំណោម “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ តាមទស្សនៈរបស់សហព្រះរាជអាជ្ញា តាមរយៈមុខតំណែងជាអ្នកដឹកនាំនៅតាមថ្នាក់ស្រុក និងថ្នាក់តំបន់ទាំងនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ - ដែលបានផ្តល់ដល់រូបគាត់នូវការគ្រប់គ្រងលើកម្លាំងប្រដាប់អាវុធជាច្រើននាក់ និងលើជីវិតប្រជាជនស៊ីវិលជាច្រើនម៉ឺននាក់ អ៊ឹម ចែម ដើរតួសំខាន់នៅក្នុងការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មដែលបណ្តាលឲ្យមានការស្លាប់អស់ជាច្រើនពាន់នាក់។

អ្វីដែលតទៅនេះគឺជាសេចក្តីសង្ខេបនៃអំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងថាតើហេតុអ្វីបានជា, តាមទស្សនៈរបស់សហព្រះរាជអាជ្ញា, អ៊ឹម ចែម ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ យ៉ាងណាក៏ដោយ វាជាការទទួលខុសត្រូវរបស់សហចៅក្រមស៊ើបអង្កេត ធ្វើការវិភាគផ្ទាល់របស់គាត់ទៅលើភស្តុតាង និងកំណត់ថាតើមានភស្តុតាងគ្រប់គ្រាន់ហើយឬនៅ ដែលថា អ៊ឹម ចែម ត្រូវទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងឆ្លើយតបតាមលក្ខខណ្ឌតម្រូវសម្រាប់អនុវត្តនូវយុត្តាធិការរបស់តុលាការ ដើម្បីបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះ។ សេចក្តីសង្ខេបនេះ មិនរាប់បញ្ចូលនូវទស្សនៈរបស់មេធាវីការពារក្តីនោះទេ ដែលពួកគាត់នឹងមានឱកាសផ្ទាល់ខ្លួន ដើម្បីធ្វើសេចក្តីសន្និដ្ឋានពីទស្សនៈរបស់ពួកគាត់លើភស្តុតាង។

ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អ៊ឹម ចែម កាន់មុខតំណែងទទួលខុសត្រូវដែលផ្តល់លទ្ធភាពឲ្យគាត់ធ្វើការចូលរួមចំណែកសំខាន់ក្នុងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងតំបន់ដែលគាត់អនុវត្តសិទ្ធិអំណាចរបស់គាត់។ នៅក្នុងរចនាសម្ព័ន្ធឋានានុក្រមអំណាចរបស់ បកក កម្ពុជាប្រជាធិបតេយ្យត្រូវបានបែងចែកជាភូមិភាគ ដែលត្រូវបានបែងចែកបន្តទៀតជាតំបន់ និងត្រូវបានបន្តបែងចែកជា ស្រុក។ នៅខាងលើថ្នាក់ភូមិភាគ គឺគណៈមជ្ឈិម ដែលជាថ្នាក់ខ្ពស់បំផុតនៃរចនាសម្ព័ន្ធអំណាចរបស់ បកក។ នៅខាងក្រោមថ្នាក់ស្រុក គឺមានការបែងចែកបន្តបន្ទាប់ទៀតជា ឃុំ សហករណ៍ និងភូមិ។ អ៊ឹម ចែម គឺជាលេខាស្រុក (មេដឹកនាំស្រុក) ក្នុងស្រុកកោះអណ្តែត ក្នុងតំបន់ ១៣ នៃភូមិភាគនិរតី និងក្រោយមកទៀតក្នុងស្រុកព្រះនេត្រព្រះក្នុងតំបន់៥ នៃភូមិភាគពាយ័ព្យ។ លេខាស្រុកត្រូវបានគេចាត់ទុកថាជាថ្នាក់សំខាន់មួយនៃថ្នាក់ដឹកនាំរបស់ បកក ដោយយោងទៅលើឋានៈរបស់ពួកគេជាចំណងទាក់ទងរវាងសហករណ៍ និងថ្នាក់លើរបស់ខ្មែរក្រហម។ ក្នុងពេលដំណាលគ្នាដែលរូបគាត់ជាលេខាស្រុក អ៊ឹម ចែម គឺជាសមាជិកគណៈតំបន់ ១៣ នៅក្នុងភូមិភាគនិរតី និងក្រោយមកទៀតជាសមាជិកគណៈតំបន់ ៥ និងបន្ទាប់មកជាអនុលេខាតំបន់ ៥ ក្នុងភូមិភាគពាយ័ព្យ។ សមាជិកគណៈតំបន់ជាទូទៅ គឺជាមុខតំណែងខ្ពស់ជាងគេបំផុតទីបី នៅក្នុងតំបន់ ហើយអនុលេខា គឺជាមុខតំណែងខ្ពស់ជាងគេទីពីរ។ គណៈតំបន់មានសិទ្ធិអំណាចរាល់បញ្ហាទាំងអស់ –យោធា និងស៊ីវិល– នៅក្នុងតំបន់របស់ពួកគេរៀងៗខ្លួន។ តួនាទីនីមួយៗ ដែល អ៊ឹម ចែម កាន់កាប់នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យនោះ ត្រូវបានចាត់តាំងដោយ តាម៉ុក ឬ ប៉ុល ពត ដែលបង្ហាញឲ្យឃើញអំពីចំណងទាក់ទងរបស់គាត់ជិតស្និទ្ធនឹងថ្នាក់ដឹកនាំខ្ពស់បំផុតរបស់ បកក និងទំនុកចិត្តដែលមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមានចំពោះ អ៊ឹម ចែម ក្នុងការអនុវត្តគោលនយោបាយរបស់ បកក។

យោងតាមការវិភាគរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ការទទួលខុសត្រូវរបស់ អ៊ឹម ចែម នៅក្នុងភូមិភាគនិរតី និងពាយ័ព្យ គ្របដណ្តប់ស្ទើតែរយៈពេលទាំងមូលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ទទួលខុសត្រូវចំពោះព្រឹត្តិការណ៍នៅក្នុងស្រុកកោះអណ្តែត និងតំបន់១៣ ក្នុងភូមិភាគនិរតី ក្នុងឋានៈជាមន្ត្រីថ្នាក់ស្រុក និងថ្នាក់តំបន់ ពីឆ្នាំ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧។ ការណ៍នេះរួមបញ្ចូលសិទ្ធិអំណាចលើមន្ទីរសន្តិសុខ វត្តអង្គសិរីមាលី ដែលខ្មែរក្រោមជាពិសេសត្រូវបានកំណត់គោលដៅ ឃុំឃាំង និងសម្លាប់ចំនួនច្រើន។ ក្នុងពាក់កណ្តាលឆ្នាំ ១៩៧៧ អ៊ឹម ចែម ត្រូវបានជ្រើសរើសដោយថ្នាក់ដឹកនាំ បកក ឱ្យដឹកនាំការបោសសម្អាតក្នុងភូមិភាគពាយ័ព្យ ដែលបណ្តាលឱ្យមានការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់កម្មាភិបាលខ្មែរក្រហម និងគ្រួសាររបស់ពួកគេជាច្រើន។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៩ អ៊ឹម ចែម បានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មនានានៅក្នុងស្រុកព្រះនេត្រព្រះ និងតំបន់៥ ក្នុងភូមិភាគពាយ័ព្យ តាមរយៈការប្រើប្រាស់មុខតំណែងថ្នាក់ស្រុក និងតំបន់របស់គាត់។ ការចូលរួមចំណែករបស់គាត់ក្នុងឧក្រិដ្ឋកម្មរួមមាន ការជួយបង្កើតមន្ទីរសន្តិសុខភ្នំត្រយោង ដែលជាមន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខធំជាងគេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាការត្រួតត្រាមើលមន្ទីរសន្តិសុខចក្រី វត្តព្រះនេត្រព្រះ និងវត្តចំការខ្នុរ។ បុគ្គលរាប់ពាន់នាក់ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងសម្លាប់ចោលតាមទំនើងចិត្តនៅក្នុងតំបន់ទាំងនេះ និងតំបន់ផ្សេងទៀតស្ថិតក្រោមការទទួលខុសត្រូវរបស់គាត់។ អ៊ឹម ចែម ក៏ផ្តួចផ្តើមឱ្យមានការសាងសង់ទំនប់ស្ពានស្រែង និងអាងទឹកព្រៃរនាម និងបានចាត់តាំងកម្មករជាច្រើនទៅធ្វើការនៅទំនប់ត្រពាំងថ្មផងដែរ។ បុគ្គលរាប់ពាន់នាក់ត្រូវបានបង្ខំឱ្យធ្វើពលកម្មនៅតាមគម្រោងស្រោចស្រប់ធំៗទាំងនេះ និងការដ្ឋានផ្សេងទៀតដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ អ៊ឹម ចែម ក្នុងលក្ខខណ្ឌបង្កើតបានជាការធ្វើឱ្យទៅជាទាសករ។ ឧក្រិដ្ឋកម្មដែល អ៊ឹម ចែម បានធ្វើ រួមមាន ការសម្លាប់នូវជាតិពន្ធុវៀតណាម និងអ្នកដែលគេសន្មត់ថាមានទំនាក់ទំនងជាមួយវៀតណាម អ្នកដែលជាប់ទាក់ទងនឹងរបប លន់ នល់ និងអ្នកដែលគេជឿជាក់តាមហេតុផលផ្សេងៗថាជា “ខ្មាំង” របស់ បកក។ បុគ្គលជាច្រើនត្រូវបានគេបង្ខំឱ្យរៀបការនៅតាមទីតាំងជាច្រើនស្ថិតក្រោមការគ្រប់គ្រងរបស់ អ៊ឹម ចែម ដោយអាពាហ៍ពិពាហ៍ដោយបង្ខំជាច្រើនក្នុងចំណោមនោះ នាំឱ្យមានការរំលោភសេពសន្ថវៈ។ ឧក្រិដ្ឋកម្មទាំងអស់នេះមិនមែនជាឧបទ្ទវហេតុដាច់ដោយឡែកនោះទេ ប៉ុន្តែបានកើតឡើងជាលក្ខណៈប្រព័ន្ធ នៅទូទាំងរយៈកាលនៃការកាន់កាប់តំណែងនៃសិទ្ធិអំណាចរបស់ អ៊ឹម ចែម។

សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ឧក្រិដ្ឋកម្មដែល អ៊ឹម ចែម ទទួលខុសត្រូវបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃ៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំ

ឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត នៃ៖ អាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ ការបាត់ខ្លួនដោយបង្ខំ និងការឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ ក៏ដូចជា ឧក្រិដ្ឋកម្មសង្គ្រាមនៃ៖ អំពើមនុស្សឃាតដោយចេតនា ការធ្វើបាបអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា អ៊ឹម ចែម ជាប់ពាក់ព័ន្ធនឹងផែនការឧក្រិដ្ឋកម្មរួម ជាមួយនឹងកម្មាភិបាល បកក ផ្សេងទៀត ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះទាំងនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានធ្វើឡើងដើម្បីលុបបំបាត់ខ្មាំង និងអ្នកប្រឆាំងទៅនឹងថ្នាក់ដឹកនាំខ្មែរក្រហម និងដើម្បីអនុវត្តគោលនយោបាយកសិកម្ម សេដ្ឋកិច្ច និងសង្គមដាច់ខាតរបស់ បកក។ សហព្រះរាជអាជ្ញាអន្តរជាតិក៏អះអាងផងដែរថា អ៊ឹម ចែម មានផែនការញុះញង់ បញ្ជា និងជួយនិងជម្រុញការប្រព្រឹត្តិបទឧក្រិដ្ឋ និងទទួលខុសត្រូវខាងព្រហ្មទណ្ឌក្នុងឋានៈដែលគាត់ជាថ្នាក់លើរបស់អ្នកប្រព្រឹត្តបទល្មើស បានដឹងឮអំពីឧក្រិដ្ឋកម្ម និងខកខានមិនបានចាត់វិធានការសមហេតុផលដើម្បីរារាំងឧក្រិដ្ឋកម្មទាំងនោះ ឬដាក់ទណ្ឌកម្មអ្នកដែលទទួលខុសត្រូវទាំងនោះ។

ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ មានចំនួន ១៣៦ ទំព័រស្តីពីការវិភាគលើអង្គសេចក្តី អមដោយការលើកឡើងចំនួន ២.៣៥១ ចំពោះភស្តុតាងដែលបានប្រមូលក្នុងអំឡុងពេលនៃកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត។ ភស្តុតាងនៅក្នុងកិច្ចស៊ើបសួររបស់ អ៊ឹម ចែម រួមមានប្រមាណជា ១.៤៥០ កំណត់ហេតុស្តាប់ចម្លើយសាក្សី ក៏ដូចជាមានយ៉ាងច្រើនផងដែរ៖ កំណត់ត្រា បកក និងកម្ពុជាប្រជាធិបតេយ្យនាសម័យកាលនោះ, បញ្ជីឈ្មោះអ្នកទោសស-២១, បទសម្ភាសន៍ និងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា, ប្រតិចារឹកសវនាការពីសំណុំរឿង០០១, ០០២/០១ និង០០២/០២, រូបថត, ផែនទី ព្រមទាំង សៀវភៅ និងអត្ថបទសិក្សាស្រាវជ្រាវ។ ក្នុងចំណោមភស្តុតាងជាច្រើនសន្ធឹកនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានកំណត់អត្តសញ្ញាណលើអ្នកដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨៧ នាក់ ដែលបានរៀបរាប់ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតាមទីកន្លែងនានា នៅពេលដែលនៅក្រោមសិទ្ធិអំណាចរបស់ អ៊ឹម ចែម។ ជនរងគ្រោះជាច្រើននាក់ បានកំណត់អត្តសញ្ញាណយ៉ាងជាក់លាក់ថាឈ្មោះ អ៊ឹម ចែម នេះជាបុគ្គលដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើពួកគាត់ និងក្រុមគ្រួសាររបស់ពួកគាត់។ ក្នុងគោលបំណងដើម្បីទទួលស្គាល់បុគ្គលទាំងនោះដែលបានមករៀបរាប់ពីទុក្ខសោករបស់ពួកគាត់ ពាក្យសុំទាំងនោះត្រូវបានសង្ខេប និងបានភ្ជាប់ជាឧសម្ព័ន្ធ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ សហព្រះរាជអាជ្ញាអន្តរ

ជាតិ មានចេតនាសុំឲ្យ សហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួន និងចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួននេះ ឲ្យទៅជាសាធារណៈ បន្ទាប់ពីការកោសលុបត្រឹមត្រូវមួយត្រូវបានធ្វើឡើងដើម្បីការពារសន្តិសុខ និងឯកជនភាពរបស់សាក្សី និងជនរងគ្រោះ។

ខាងលើនេះជាសេចក្តីសង្ខេបពីទស្សនៈរៀងៗខ្លួនរបស់សហព្រះរាជអាជ្ញា។ អ្នកអានគួរត្រូវរំលឹកថា ការណ៍នេះមិនរាប់បញ្ចូលនូវទស្សនៈរបស់មេធាវីការពារក្តីនោះទេ។ បន្ថែមលើនេះ សេចក្តីសង្ខេបលើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានេះ គឺមិនមានចេតនាឆ្លុះបញ្ចាំងពីទស្សនៈរបស់សហចៅក្រមស៊ើបអង្កេត ដែលពួកគាត់ត្រូវធ្វើការកំណត់ផ្ទាល់ខ្លួនអំពីបញ្ហាទាំងនេះ។

ព័ត៌មានបន្ថែម សូមទាក់ទង៖


| | |
|---|---|
| **អ្នកស្រី ហាយ៉ាត់ អាពូ សាឡេះ** | **លោក នេត្រ ភក្ត្រា** |
| មន្ត្រីព័ត៌មានសាធារណៈ | មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម |
| លេខទូរសព្ទ៖ +៨៥៥(0) ១២ ៤៨៨ ៩៣៦ | +៨៥៥(0) ១២ ៤៨៨ ១៥៦ |
| ទូរសព្ទលើតុ៖ +៨៥៥(0) ២៣ ៨៦១ ៥៥ | +៨៥៥(0) ២៣ ៨៦១ ៥៦៤ |
| សារអេឡិចត្រូនិក: abusaleh@un.org | សារអេឡិចត្រូនិកneth.pheaktra@eccc.gov.kh |